# កិច្ចសីល

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



ព្រះវិហារវត្តឧត្តរាវតី

២១៤.
១០

ព.ស ២៥៤០ គ.ស ១៩៩៧

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh**    **www.elibraryofcambodia.org**

សូ១៤.១០

# និច្ចសីល

LIBRARY
BUDDHIST INSTITUTE

ស្រាវជ្រាវចងក្រងដោយ

ជា គាន

បោះពុម្ពចែកផ្សាយជាធម្មទានក្នុងពិធីសម្ពោធ

## ព្រះវិហារវត្តឧត្តរាវតី

សង្កាត់ឫស្សីកែវ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

នៅថ្ងៃ សៅរ៍-អាទិត្យ-ច័ន្ទ ៧-៨ និង ៩ កើត

ខែផល្គុន ព.ស ២៥៤០ ត្រូវនឹងថ្ងៃទី ១៥-១៦

និង ១៧ ខែ មីនា ឆ្នាំ ១៩៩៧

ព.ស ២៥៤០ គ.ស ១៩៩៧

# អារម្ភកថា

**វត្តឧត្តរាវតី** សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ត្រូវបានចាប់ផ្តើមកសាងឡើងវិញ តាំងពីឆ្នាំ ១៩៧៩ កន្លងមក ។ ទីសេនាសនៈទាំងឡាយនៅក្នុងវត្ត បានជួសជុល និងកសាងថ្មី មានការរីកចំរើនគួរឱ្យមានមោទនភាព និង គួរជាទីជ្រះថ្លា ។

ព្រះសង្ឃ អាចារ្យ គណៈកម្មការ និង ពុទ្ធបរិស័ទចំណុះជើងវត្តទាំងមូល បានប្រារព្ធពិធីបុណ្យសម្ពោធយ៉ាងមហោឡារិក ក្នុងរយៈពេល ៣ ថ្ងៃ គឺថ្ងៃ ៧-៨ និង ៩ កើត ខែផល្គុន ព.ស ២៥៤០ ត្រូវនឹងថ្ងៃទី ១៥-១៦ និង ១៧ ខែមីនា ឆ្នាំ១៩៩៧ ដើម្បីពង្រីកកុសលនេះ ឱ្យកាន់តែរីកចំរើនប្រសើរឡើងថែមទៀត ។

សម្តេច **ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានរដ្ឋសភា និងជាប្រមុខរដ្ឋស្តីទី បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបង្ហូតទង់មួយគូ កាត់ខ្សែបូរ និងរាប់បាត្រព្រះសង្ឃ ៦៧ អង្គ ព្រមទាំងបានជួបសំណេះសំណាលសួរសុខទុក្ខ ព្រះសង្ឃ មន្ត្រីរាជការ និងប្រជាពលរដ្ឋ ក្នុងពេលនោះផង ។

សម្តេចព្រះពោធិវង្ស **នន់ ង៉ែត** ព្រះមេគណក្រុងភ្នំពេញ, សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុំ ស៊ុំ** អគ្គាធិការនៃពុទ្ធិកសិក្សា, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ** នាយកពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត លោកគ្រូធម្មាចារ្យ **ប៊ុត សាវង្ស** បាននិមន្ត និង អញ្ជើញសំដែងព្រះធម៌ទេសនានិងស្វាធ្យាយជយន្តោប្រសិទ្ធពរជ័យ ។

ព្រះសង្ឃ អាចារ្យ គណៈកម្មការ និង ពុទ្ធបរិស័ទចំណុះជើងវត្ត មានសំណូមពរចង់បានអត្ថបទធម៌ ដើម្បីចែកផ្សព្វផ្សាយជាធម្មទាន នៅក្នុងឱកាសពិធីបុណ្យសម្ពោធនេះ ។

ខ្ញុំព្រះករុណាខ្ញុំបាទ ក៏បានដកស្រង់អត្ថបទទស្សនវិជ្ជាពុទ្ធសាសនា របស់ព្រះមហាវីរិយបណ្ឌិតោ **ជាំង ខាត់** ស្តីពីខ្លឹមសារនិច្ចសីល ឬ សីលប្រាំ មកចងក្រងជាសៀវភៅដ៏តូចនេះ ភ្ជាប់ជាមួយនឹងទិដ្ឋភាពរួម របស់វត្តឧត្តរាវតី ដើម្បីទុកជាឯកសារ ដ៏មានសារប្រយោជន៍សម្រាប់ ព្រះសង្ឃ ពុទ្ធបរិស័ទ ត្រិះរិះពិចារណាសិក្សាស្រាវជ្រាវតទៅអនាគត។

សូមលើកយកកុសលនេះ ប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជូនសម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និង ពុទ្ធបរិស័ទជិតឆ្ងាយទាំងអស់ សូមបានប្រកបដោយពរទាំង ៥ ប្រការគឺ: អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ ជានិច្ចនិរន្តរ៍តរៀងទៅ ។

សូមព្រះពុទ្ធសាសនា ចំរើនរុងរឿងជានិច្ច ។

សូមសុខសន្តិភាព កើតមាន ដល់មាតុភូមិ និង ប្រជាពលរដ្ឋខ្មែរ គ្រប់ពេលវេលា ។

ព.ស ២៥៤០

**វត្តឧត្តមរាវតី** , ថ្ងៃទី ១២ ខែមីនា

គ.ស ១៩៩៧

អ្នករៀបរៀង

**ជាំ គាន**

# ប្រវត្តិវត្តឧត្តរាវតី

--⊛--




ខ្លោងទ្វារចូលវត្តជាប់ផ្លូវជាតិលេខ ៥

នៅឆ្នាំ ១៩៤៣-៤៤ មានពុទ្ធបរិស័ទមួយចំនួន នៅជុំវិញវត្តឧត្តរាវតី ដែលនៅពេលនោះ ពុំទាន់មានវត្តនៅឡើយ គេហៅថា ភូមិម៉ាស៊ីនស្រូវ ។ មានលោកតាម្នាក់ឈ្មោះ តា សឿ គាត់មានដីមួយ



ខ្លោងទ្វារជាប់របងវត្ត

កន្លែងត្រង់វត្តឧត្តរាវតីនេះ។ លោក តា ស្នើ ដោយរួមទាំងឧបាសិកាខ្លះ មានឧបាសិកា ជូយ ឧបាសិកា ឃឹម, ឧបាសិកា នួច ដែលសុទ្ធសឹងជាអ្នកមានសទ្ធាមុតមាំក្នុងព្រះពុទ្ធសាសនា ក៏បានរួមរួមគ្នាផ្ដើមកសាងសាលាបុណ្យមួយខ្នង នៅលើដី តា ស្នើ ។ ពុទ្ធបរិស័ទទាំងនោះ

មានសេចក្តីជ្រះថ្លាចំពោះលោកគ្រូអាចារ្យ **ឈឹម វ៉ន** គង់នៅវត្តសារាវ័នតេជោ ក្រុងភ្នំពេញ ហើយក៏បាននិមន្តលោកគ្រូអង្គនេះ មកប្រទានសីលរៀងរាល់ថ្ងៃសីល ។

កាលណាមានព្រារព្ធពិធីបុណ្យទានអ្វីផ្សេងៗ តែងជ្រះថ្លាមកនិមន្តព្រះសង្ឃពីវត្តសារាវ័ន ហើយជាពិសេស នៅពេលបុណ្យភ្ជុំបិណ្ឌ តែងបាននិមន្តលោកគ្រូ **ឈឹម វ៉ន** និង ព្រះសង្ឃដទៃទៀត មកបំពេញ



**របងវត្ត**



ជខធខ់

កុសលតាមសទ្ធារបស់ខ្លួនរៀងរាល់ថ្ងៃ ។

នៅឆ្នាំ១៩៤៥ ពុទ្ធបរិស័ទទាំងនោះ បាននិមន្តលោកគ្រូ **ឈឹម រ៉ែន** ព្រមទាំងសិស្សានុសិស្សពីវត្តសារាវ័នតេជោ ទៅគង់នៅសាលាបុណ្យនោះ



ព្រះវិហារ

ហើយនាំគ្នាបំពេញ កុសលផ្សេងៗ រៀងមក ។ ក្រោយមក, អ្នកទាំងនោះមានសទ្ធាជ្រះថ្លាខ្លាំងណាស់ ក៏នាំគ្នាចាប់ផ្ដើមកសាងវត្តឡើង ។ ប៉ុន្តែ ជាដំបូងកសាងជាសាឡមួយបណ្ដោះអាសន្ន ដោយមានព្រះសង្ឃខ្លះ ត្រូវជាសិស្សគណលោកគ្រូ **ឈឹម វ៉ែន** មានជាអាទិ លោកគ្រូ **មង់ ស៊ាន**, លោកគ្រូ **ឡុង ឱ** សម្ដេចព្រះមង្គលទេពាចារ្យ **អ៊ុម ស៊ុម**

(កាលណោះសម្តេចនៅជាភិក្ខុសាមញ្ញនៅឡើយ) លោកគ្រូអាចារ្យ ស៊ឹម បានចាប់ផ្តើមកសាងសាឡាមនេះឡើង ដោយមាន តា ឪស្សី យាយ ថូយ យាយ ឃឹម , យាយ ឌូច ជាអ្នកឧបត្ថម្ភពេញទំហឹង ។

ពីមុនមក, វត្តនេះ មិនមានទំហំធំដូចសព្វថ្ងៃនេះទេ នៅផ្នែកខាងជើង មានរបងដើមអំពិលទឹក ។ ដោយឃើញថា ទីវត្តនេះមានទំហំតូច ក្រោយមកក៏មានពុទ្ធបរិស័ទ មានសទ្ធាជ្រះថ្លាខ្លះ មិនចាំឈ្មោះ ក៏បានជាវដីខាងជើងវត្តនេះ បព្ចាលមកជាដីរបស់វត្ត ។ រីឯរបងអំពិលទឹកនោះ



បណ្ណាល័យ និង សាលាពុទ្ធិកបឋមសិក្សា



សមណសិស្សកំពុងសិក្សា

ក៏គេបានរំលាយចោលទៅ ។ អាស្រ័យដោយមានរបងដើមអំពិលទឹក ស្ថិតនៅខាងជើងព្រះវិហារ ទើបលោកគ្រូ **ឈឹម រ៉ែ** ដាក់នាមវត្តនោះថា **ខត្តឧត្តរាខត** រហូតមកដល់បច្ចុប្បន្ននេះ ។

ដោយការប្រឹងប្រែង របស់លោកគ្រូ **ឈឹម រ៉ែ** និងព្រះសង្ឃជាសិស្សគណ ព្រមទាំងមានពុទ្ធបរិស័ទជួយឧបត្ថម្ភខ្លាំងក្លាផង ទើបវត្តនេះបានក្លាយទៅជាវត្ត មានទីសេនាសនៈគួរដល់ការស្នាក់អាស្រ័យនៃសង្ឃ និង គួរដល់ការជ្រះថ្លានៃពុទ្ធបរិស័ទ ។ តមក , ក៏ចាប់ផ្តើម

កសាងព្រះវិហារជាថ្មី រហូតដល់បានសំរេច ដែលស្ថិតនៅរហូតសព្វថ្ងៃនេះ ។

ប៉ុន្តែជាអកុសល ក្នុងកំឡុង ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ក្រោមរបបប្រល័យពូជសាសន៍ប៉ុលពត វត្តឧត្តរាវតី ត្រូវទទួលរងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ ។ ទីសេនាសនៈ គម្ពីរដីកា ក្បួនច្បាប់ផ្សេងៗ ត្រូវបំផ្លិចបំផ្លាញអស់ នៅសល់តែតួព្រះវិហារមួយប៉ុណ្ណោះ ។

ក្រោយថ្ងៃជ័យជំនះ ៧ មករា ១៩៧៩ អាស្រ័យដោយគុណ



កុដិលោកគ្រូចៅអធិការ



កុដិលោកគ្រូសូត្រស្តាំ

បុណ្យរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ពុទ្ធបរិស័ទចំណុះជើងវត្ត ក៏បានរៀបចំកសាងវត្តឧត្តរាវតីនេះឡើងវិញ ប្រែក្លាយទីនេះឱ្យទៅជាទីអារាម មានការរីកចំរើន មានសោភណភាពគួរជាទីរីករាយ និងជ្រះថ្លា និងមានព្រះសង្ឃគង់នៅសិក្សារៀនសូត្រព្រះបរិយត្តិធម៌ គោរពប្រតិបត្តិ ទ្រទ្រង់ធម៌វិន័យរហូតដល់សព្វថ្ងៃនេះ ។

យើងបានរៀបចំទីតាំងវត្តទាំងមូលដែលពីមុនក្រហេងក្រហូង ព្រៃស៊ុប

ទ្រុប ដោយបានកសាងក្លោងទ្វារមួយនៅជាប់ថ្នល់ជាតិលេខ៥ ផ្លូវចូលវត្ត កសាងរបង និង ក្លោងទ្វារនៅផ្នែកខាងកើត, ជងទង់មួយគូដីខ្ពស់ស្កឹមស្កៃ ជួសជុលព្រះវិហារ ដែលពីមុននៅសល់តែតួព្រះវិហារនោះ ឱ្យមានខឿន ជើងទៀនព័ទ្ធជុំវិញ បំពាក់ក្បាច់រចនា គូរគំនូរខាងក្នុងដ៏ស្រស់ស្អាត កសាងសាលាពុទ្ធិកបឋមសិក្សាពីរជាន់ ជាន់ក្រោមជាបណ្ណាល័យ និង ជាន់លើសំរាប់សមណសិស្សរៀនសូត្រ , ឧបដ្ឋានសាលាពីរខ្នង ,



កុដិរលោកគ្រូសូត្រឆ្វេង



ឧបដ្ឋានសាលា

កុដិធំ ៣ ខ្នង, ឈាបនដ្ឋានសំរាប់បូជាសព ។

ព្រះសង្ឃ អាចារ្យ គណៈកម្មការ និង ពុទ្ធបរិស័ទចំណុះជើងវត្ត មានគំរោងនឹងកសាងទីតាំងសមធិដ្ឋានមួយ នៅផ្នែកខាងក្រោយ អោយមានលក្ខណៈសមរម្យ សំរាប់ជាកន្លែងអប់រំបន្ទំអារម្មណ៍ចាស់ព្រឹទ្ធាចារ្យ ដែលមានសទ្ធាជ្រះថ្លា និង កសាងផ្លូវថ្នល់មួយខ្សែជាប់របងវត្ត ផ្នែកខាង



សាលាធម្មសភា

ត្បូង ដើម្បីស្រួលងាយក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋយើង ។

តទៅអនាគត, ព្រះសង្ឃ អាចារ្យ គណៈកម្មការ និងពុទ្ធបរិស័ទ ចំណុះជើងវត្ត នឹងខិតខំកសាង រៀបចំវត្តឧត្តរារតីនេះ ដើម្បីឆ្លើយតប យ៉ាងសក្តិសមទៅនឹងតួនាទីរបស់វត្ត និង របស់ព្រះសង្ឃ ។

# និ ច្ច សី ល

LIBRARY

ព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ ទ្រង់ជាទេសនាកោសល្យ ព្រះអង្គទ្រង់បានសំដែងចំពោះសក្យមហានាមថា “ ម្នាលមហានាម ឧបាសកឯណា បានវៀរចាកបាណាតិបាត គឺមិនសម្លាប់សត្វ ១, វៀរចាកអទិន្នាទាន គឺមិនលួចទ្រព្យអ្នកដទៃ ១, វៀរចាកកាមេសុមិច្ឆាចារ គឺ មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១, វៀរចាកមុសាវាទ គឺមិននិយាយកុហក ១ វៀរចាកសុរាមេរយៈ គឺមិនផឹកនូវសុរា និង មេរ័យ ១ ឧបាសកនោះ ឈ្មោះថា ឧបាសកមានសីល ” ។

បញ្ចាវិរតិចេតនា គឺចេតនាដែលវៀរចាកវេរា ៥ ឈ្មោះថា ជា “ សីលនៃឧបាសក ” ។

**សីលេន សុគតឹ យន្តិ** **សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ** **តស្មា សីលំ វិសោធយេ** ។

សត្វទាំងឡាយ បានទៅកាន់ស្ថានសួគ៌ ក៏ព្រោះសីល, សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មង ។

សីលនេះ ជាខាងដើមនៃកុសលធម៌ទាំងពួង ជាធម៌សាងមេត្តាករុណា សាងសាមគ្គី សាងសេចក្តីស្រឡាញ់រាប់អានគ្នា ឱ្យកើតមាន

ទូទៅពេញសាកលលោក សាងសេចក្តីសុខចំពោះសព្វសត្វដែលមានជីវិត ។ ធម៌នេះ ប្រសើរណាស់ តែគួរអោយស្តាយពន់ពេកដោយយើងមិនទាន់បាន បំពេញធម៌នេះអោយបានពេញលេញតាមពុទ្ធបំណងនៅឡើយ ។

ព្រះសម្ពុទ្ធ ទ្រង់សំដែងធម៌ប្រោសសត្វ ដោយមានពុទ្ធបំណងថា ធម៌ របស់ព្រះអង្គនេះ និងបានជាប្រយោជន៍ បានសេចក្តីសុខចំរើន និង បាន អនុគ្រោះដោយផលច្រើនទៀត ។

ពុទ្ធសាសនាបានឧទ្ទានថា មនុស្សម្នាក់ៗ ត្រូវចេះកសាងខ្លួន **"អត្តសម្មាបណិធិ"** អោយបានល្អប្រសើរយ៉ាងសុក្រិតដោយធម៌ពីរប្រការ គឺករុណា និង បញ្ញា ។

ករុណា ជាធម៌សាងអោយចេះស្រឡាញ់គ្នា ធ្វើចិត្តអោយបាន ទូលាយ ធ្វើចិត្តអោយល្អពិសេស ធ្វើចិត្តអោយចេះស្រឡាញ់ និងសន្តោស គ្នាទៅវិញទៅមក ។ ធម៌ទាំងនេះហើយដែលធ្វើអោយមនុស្សមានគុណ សម្បត្តិប្រសើរខ្ពង់ខ្ពស់ខាងផ្លូវចិត្ត ឬ គុណសម្បត្តិរបស់ចិត្ត ។

បញ្ញា ជាធម៌សំរាប់កសាងមនុស្សឱ្យមានការឈ្លាសវៃ ឱ្យមានពន្លឺ មើលឃើញអ្វីៗតាមយថារភូត ( **យថាភូតំ បជានាតិ** ) ។ ធម៌ទាំង នេះហើយ ដែលធ្វើមនុស្សឱ្យមានគុណសម្បត្តិខាងមុខវិជ្ជា ។

បុគ្គលណាខំប្រតិបត្តិតែខាងធម៌ ដែលធ្វើឱ្យកើតការស្រឡាញ់រាប់ អានគ្នាតែម្យ៉ាង មិនទីកនាប្រតិបត្តិធ្វើឱ្យកើតវិជ្ជា បុគ្គលនោះនិងទៅជា

មនុស្សចិត្តល្អ តែល្ងង់ខ្លៅមើលទៅឃើញដូចផ្កា ដែលមានពណ៌ស្រស់ តែឥតក្លិន ក្រអូប ។

បុគ្គលណា ខំប្រតិបត្តិតែខាងធម៌ ឱ្យកើតពន្លឺ មានប្រាជ្ញាឈ្លាសវៃ តែម្យ៉ាង មិននឹកនាប្រតិបត្តិធម៌ដែលធ្វើឱ្យកើតការស្រឡាញ់រាប់អានគ្នា បុគ្គលនោះនឹងទៅជាមនុស្សមានបញ្ញាជាពន្លឺក្នុងចិត្ត តែសមានចិត្តរឹង រឹងរូស ឃោរឃៅឃ្មឹងឃ្មង មិនគិតដល់អ្នកដទៃឡើយ ចិត្តកាចដូចសត្វសាហាវ ។

ដូច្នេះបុគ្គលម្នាក់ៗ លុះត្រាតែប្រតិបត្តិធម៌ទាំងពីរប្រការនេះ ទើបមានគុណសម្បត្តិដ៏ប្រសើរដូចផ្កាដែលមានពណ៌ល្អផង មានក្លិនក្រអូបផង ។

នេះជាពុទ្ធបំណងដែលទ្រង់ចង់បាន ឱ្យកើតមានឡើងនៅក្នុងជីវលោកនេះ ។ ធម៌ទាំងពីរប្រការ គឺករុណា និង បញ្ញា ជាធម៌មានបច្ច័យទាក់ទងគ្នាទៅវិញទៅមក ។

រីឯពាក្យថា សីលបានដល់មេត្តា និងករុណាមានកត្តាបីប្រការនៃអដ្ឋង្គិកមគ្គ គឺ **សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ** ។

ក-**សម្មាវាចា** សំដីត្រឹមត្រូវបានដល់ការវៀរចាកវចីទុច្ចរិត ការពោលពាក្យប្រកបដោយទោស ៤ យ៉ាង :

១-"វៀរពោលពាក្យមិនពិត" គឺនិយាយតែពាក្យណាជាពាក្យពិត ពាក្យដែលធ្វើឱ្យគេស្រឡាញ់រាប់អាន ។ មនុស្សទូទៅ ពេញចិត្តនឹងពាក្យពិត ពាក្យពិតជាទីស្រឡាញ់នៃមនុស្សទូទៅ។ បើមនុស្សស្រឡាញ់រាប់អាន

គ្នាហើយ លោកនេះនឹងបានសេចក្តីសុខបរិបូណ៌ ។

២-"វៀរពោលពាក្យសិកសៀតញុះញង់" គឺនិយាយតែពាក្យណាដែលធ្វើឱ្យគេកើតក្តីសប្បាយរីករាយ នាំឱ្យកើតក្តីសុខក្សេមក្សាន្ត នាំឱ្យមានសាមគ្គីធម៌ នាំឱ្យកើតមេត្តាចិត្តរវាងមនុស្សលោកផងគ្នា។ បើមនុស្សលោកនិយាយតែពាក្យនាំឱ្យកើតសេចក្តីសុខ ឱ្យមានសាមគ្គីគ្រប់គ្នាទូទៅ ឱ្យមានតែមេត្តាចិត្ត សង្គ្រាមលោកមិនអាចកើតឡើងបានឡើយ ។ លោកនេះនឹងសុខក្សេមក្សាន្ត និរទុក្ខ និរភ័យ ពិតប្រាកដ ។

៣-"វៀរពោលពាក្យជូចប៉ូរចៅ" គឺនិយាយតែពាក្យពីរោះ ពាក្យផ្អែមល្ហែម គួរជាទីពេញចិត្តមនុស្សទូទៅ ជួបគ្នាពេលណាមុខរីករាយដូចផ្កាឈូកទាំងអស់គ្នា ។ ពាក្យពីរោះនេះ ជាទីកបន្សាផ្សារចងមិត្តភាពធ្វើមនុស្សលោកឱ្យជាកល្យាណមិត្តនឹងគ្នា ។ បើមនុស្សលោកជាកល្យាណមិត្តគ្នាហើយ មិនអាចមានសង្គ្រាមលោកទេ ។ ក្តីសុខក្សេមក្សាន្តនឹងកើតប្រាកដឡើង ។

៤-" វៀរពោលពាក្យឡេះឡោះ " គឺពោលតែពាក្យដែលមានប្រយោជន៍ មានខ្លឹមសារ ពាក្យដែលនាំឱ្យកើតសេចក្តីចំរុងចំរើន ធ្វើខ្លួនឱ្យបានប្រយោជន៍ផង ធ្វើអ្នកដទៃឱ្យបានប្រយោជន៍ផង ឬពោលពាក្យដាសតឿនក្រើនរំលឹកជនទាន់ជនឱ្យប្រព្រឹត្តល្អ កុំឱ្យធ្វើអាក្រក់។ ការពោលពាក្យប្រកបដោយប្រយោជន៍នេះ ជាការជួយមនុស្សឱ្យបានរីកចំរើនគ្រប់វិស័យ ឱ្យបានបរមសុខ នៅនាលោកនេះ ។

២-សម្មាកម្មន្តៈ "ការងារត្រឹមត្រូវ" បានដល់អំពើដ៏ប្រសើរ គឺសាងសីលធម៌ឱ្យកើតឡើងដល់មនុស្សលោក ធ្វើមនុស្សលោកនេះ ឱ្យមានកិត្តិយសខ្ពង់ខ្ពស់ ឱ្យមានអរិយធម៌ដ៏ប្រសើរ ជាហេតុនាំឱ្យកើតក្ដីសុខក្សេមក្សាន្ត ចំរុងចំរើន បរិបូណ៌ ដោយអាមិសសុខ និងនិរាមិសសុខ។ សម្មាកម្មន្តៈ ឬការងារត្រឹមត្រូវនេះ ជាធម៌នាំឱ្យវៀរអំពើអាក្រក់ទាំងអស់ ដោយផ្លូវកាយ ឬហៅថា កាយទុច្ចរិត ប្រកបដោយទោស ៣ ប្រការ គឺ :

១-"វៀរសម្លាប់សត្វមានជីវិត" ពោលគឺ គោរពឥស្សរភាពទូទៅ ព្រោះជីវិតជាទីស្រឡាញ់របស់សត្វទាំងឡាយ ។ មនុស្សសត្វស្រឡាញ់ជីវិត ស្រឡាញ់សេចក្ដីសុខ ស្អប់ខ្ពើមសេចក្ដីទុក្ខ ។ ការកាប់សម្លាប់បំបាត់ជីវិត គឺតែងមានការតបវិញ ដែលយើងហៅថា "ពៀរ" នោះ ។ ពៀរតបពៀរមិនមានទីបំផុតទេ ។ ការវៀរសម្លាប់បំបាត់ជីវិតគេឈ្មោះថា បំបាត់មហាភ័យ ឈ្មោះថា សាងសេចក្ដីសុខឱ្យខ្លួននិងអ្នកដទៃ ឈ្មោះថា ធ្វើវិភាគទានមួយយ៉ាងធំ ក្នុងការកសាងសេចក្ដីសុខក្សេមក្សាន្តជូនពិភពលោក ។ សត្វរងគ្រោះដែលត្រូវគេសម្លាប់ក្ដៅក្រហាយណាស់ចំពោះអ្នកសម្លាប់ តែដោយខ្លួនពុំមានអានុភាព ក៏បណ្ដោយទៅតាមយថាកម្ម ឯសត្វដែលមានអានុភាព ដូចជាខ្លា ដំរី ជាដើម មិនព្រមបណ្ដោយឱ្យមនុស្សសម្លាប់ដោយងាយទេ វាខិតខំតដៃវិញក៏ព្រោះតែវាស្រឡាញ់ជីវិត។ សេចក្ដីក្ដៅក្រហាយរបស់អ្នកត្រូវគេសម្លាប់ ផ្ដុំគ្នាកើតឡើងទៅជាភ្លើង

នរកនោះអ្នកសម្លាប់វិញឱ្យទល់ទុក្ខវេទនា ។ អំពើអាក្រក់ ឬអកុសលនេះ ជាច្បាប់ធម្មជាតិមានកម្លាំងខ្លាំងក្លាណាស់ បណ្ដាលឱ្យកើតទៅជាភ្លើងនរក ឆេះអ្នកដែលប្រព្រឹត្តអំពើអាក្រក់វិញ ។

ការធ្វើអំពើល្អ ឬ កុសលកម្ម មានការវៀរមិនសម្លាប់បំបាត់ជីវិតជាដើម ជាហេតុនាំឱ្យមានការស្រឡាញ់រាប់អានគ្នា ឈ្មោះថាសាងសេចក្ដីសុខចំពោះខ្លួន ឬសាងសេចក្ដីសុខក្សេមក្សាន្ត សាងសន្តិភាពចំពោះសង្គមមនុស្សលោកទាំងមូល ។ សង្គមមនុស្សដែលប្រកបដោយសីលធម៌ ជាសង្គមសន្តិភាពបរិបូណ៌ ដោយមិត្តភាព ជាហេតុនាំឱ្យមនុស្សលោកទៅកាន់សេចក្ដីចំរើន ជីវភាពខ្ពង់ខ្ពស់ ជាសុខភាពកើតមានសមស្របតាមសេចក្ដីប្រាថ្នាទូទៅ ។

ការគោរពឥស្សរភាពជីវិតមនុស្សរវាងមនុស្ស សង្គមរវាងសង្គម ប្រទេសរវាងប្រទេស នេះឈ្មោះថា សាងសន្តិភាពឱ្យមនុស្ស សត្វលោក ។ ពុទ្ធសាសនិកជនគួរកសាងជីវិតខ្លួនទៅតាមមាគ៌ាដ៏ប្រសើរនៃព្រះអរិយបុគ្គល មិនគួរធ្វើខ្លួនជាបន្ទា ឬឱ្យស្អុកលោកនេះទេ ។

២-"វៀរមិនកាន់យកទ្រព្យដែលគេមិនបានឱ្យ" ការគោរពកម្មសិទ្ធិអ្នកដទៃ ជាធម៌ដ៏ប្រសើរណាស់ ព្រោះថាទ្រព្យសម្បត្តិដូចរូបកាយយើងដែរ ជារបស់ដែលបុគ្គលស្ងួន រក្សាទុកដោយប្រពៃ ។ ការមិនគោរពកម្មសិទ្ធិជនដទៃ គឺការលួចឆក់ប្លន់កេងប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃ ជាហេតុបង្កឱ្យកើតក្ដីក្ដៅក្រហាយ ទុកដូចជាបង្កាត់ភ្លើងនរកឱ្យឆេះលោកនេះឡើង ។

អំពើនេះជាមហាភ័យដ៏ធំមួយ ត្រូវតែវៀរ ។ ទ្រព្យសម្បត្តិនេះ គឺជីវិតយើងគ្រប់គ្នា ។ មនុស្សរស់នៅសុខសប្បាយក្សេមក្សាន្តដោយទ្រព្យ ។ អ្នកបៀតបៀនទ្រព្យអ្នកដទៃ ឈ្មោះថា បំផ្លាញសេចក្ដីសុខគេ ហើយអ្នកនោះឈ្មោះថា ផុតបំផ្លាញខ្លួនឯងទៀត ។ ដូច្នេះអ្នកស្រឡាញ់ខ្លួនគួរប្រតិបត្តិតាមមាគ៌ាដ៏ប្រសើរ ដែលអង្គព្រះសម្ពុទ្ធបានត្រាស់ទុន្ទានទុកខាងលើនេះ ។ អ្នកនោះនិងបាននាមថា អរិយជន ជនប្រសើរក្នុងលោក ជាទីពឹងពុំនាក់ជនទូទៅ ទុកដូចជាម្លប់ដើមឈើសំរាប់ជាជំរកនៃមនុស្សសត្វទាំងឡាយ ឱ្យត្រជាក់ត្រជុំសុខដុមរមនាជាមួយគ្នាតទៅ ។

៣–"វៀរប្រព្រឹត្តកន្លងប្រពៃណី" ពោលគឺការរក្សាក្ដីបរិសុទ្ធក្នុងប្រពៃណី ។ ក្នុងសង្គមមនុស្សលោកនេះ មានធម៌ប្រកាន់ថា "ស្វាមីភរិយាជាគូជីវិត" "បុត្រធីតាជាទីស្រឡាញ់ពេញចិត្ត" ។ ការប្រព្រឹត្តិកន្លងប្រពៃណី ជាហេតុបណ្ដាលឱ្យកើតក្ដីក្ដៅក្រហាយ ។ ដូចច្នេះស្វាមីភរិយា ឬ បុត្រធីតា គួរស្ងួនរក្សាប្រពៃណីខ្លួន ទុកឱ្យបរិសុទ្ធដោយប្រពៃ ។ មនុស្សជាសត្វប្រសើរ ចេះស្គាល់ល្អអាក្រក់ គួរមិនគួរ ចេះទប់ចិត្ត រក្សាចិត្ត ដូចសារថី ចេះបរសេះ ឱ្យទៅត្រង់តាមផ្លូវល្អ មិនគួរបណ្ដែតបណ្ដោយចិត្តឱ្យចរទៅតាមទំនើងខ្លួនទេ ។ សតិសម្បជញ្ញៈទុកជាសារថី សេះទុកជាចិត្តជ្រើសទ្រនង់ កាយទុកជាតួរថ។ អ្នកប្រាថ្នាល្អ ត្រូវយកសតិសម្បជញ្ញៈជាសារថី ទប់ខ្សែគឺក្ដីប្រាថ្នា ដែលចងសេះ គឺចិត្តឱ្យនៅនឹង ហើយឱ្យចរទៅតាមផ្លូវត្រង់ ទៅរកក្ដីក្សេមក្សាន្ត ។

អ្នកដែលមានសតិសម្បជ្ញៈ ជាឆ្លាំ និងបានឡើងឋានៈ ជាអរិយបុគ្គល ជាមនុស្សមានតម្លៃខ្ពង់ខ្ពស់គួរគោរពបូជា គួរដល់ការរាប់អាននៃជនទូទៅ។

ក្នុងទីនេះ គួរបញ្ចូលការវៀរចាកសេពសុរានិងម៉េរ័យមួយមកផង ។ ការសេពសុរា និងមេរ័យនេះ ជាការបន្ថោកបន្ទាបខ្លួន ធ្វើឱ្យភាពខ្លួនជាមនុស្សត្រូវមានតម្លៃក្លាយទៅជាថោកទៅវិញ ព្រោះសុរាមានជាតិក្តៅ មានជាតិពុល អ្នកសេពសុរាដល់កំរិត រាងកាយមិនមានសុខភាព សតិបញ្ញាទន់ខ្សោយ ។ បើសតិបញ្ញាជាធម៌ដែលធ្វើឱ្យមានពន្លឺក្នុងខ្លួនចុះអន់ថយ ហើយអ្វីៗទាំងអស់ក៏ចុះដុនដាបទៅដែរ មនុស្សលែងមានភាពជាមនុស្ស ទៅជាភាពអ្វីមួយទៀតដែលមិនគួរប្រាថ្នា ។ សេចក្តីប្រាថ្នារបស់យើងដែលចង់ឱ្យបានទៅជាមនុស្សប្រសើរ ជាអរិយជននោះ ប្រាជកជាមិនមានផ្លូវនិងទៅឱ្យបានដល់ទេ ។ លាភដែលត្រូវបានជាមនុស្សទៀតខកខានលែងបាន ហើយជាមនុស្សស្អុកលោកកើតមកគ្រាន់តែចង្អៀតគេ ។

កត្តានៃមាគ៌ាទាំង ២ ប្រការគឺ **សម្មាវាចា** និង **សម្មាកម្មន្តៈ** នេះបើរួមគ្នាមិនគឺអ្វីដទៃទេ គឺការសមាទាននិច្ចសីល ឬសីលប្រាំនេះឯង។ នេះហើយជាដើមនៃកុសលធម៌ទាំងពួង ឬជាជណ្តើរទី១នៃពុទ្ធសាសនិកជនគ្រប់គ្នា ដែលត្រូវប្រតិបត្តិដើរទៅកាន់មគ្គផលនិព្វាន ។ អ្នករក្សាសីលរក្សាដោយមានបំណងនិងលាងចិត្តរបស់ខ្លួន ដែលប្រលាក់ដោយរាគៈទោសៈឱ្យជ្រះបរិសុទ្ធ ដែលជាប្រភពនៃសេចក្តីសុខ ដើម្បីធ្វើចិត្តឱ្យខិតចូលទៅជិតព្រះនិព្វាន ។ អ្នករក្សាសីលបែបនេះ ជាអរិយបុគ្គល ។ សីល

ដែលខ្លួនរក្សាជាអរិយកន្តសីល មានសីលជាទី ស្រឡាញ់ ស្រឡាញ់សីល ស្មើជីវិត ទុកសីលជាជីវិតរបស់ខ្លួន ។ ការរក្សាសីលបែបនេះឈ្មោះថា ស្មោះត្រង់ចំពោះខ្លួនឯង ។

គ-**សម្មាអាជីវៈ** "អាជីពត្រឹមត្រូវ" បានដល់ការវៀរចាកមិច្ឆាជីព គឺការចិញ្ចឹមជីវិតខុសចាកគន្លងធម៌ ។ ការស្គាល់ប្រមាណក្នុងការគ្រប់គ្រងជីវិត ជាការកម្រណាស់ មិនមែនជាការងាយទេ ។ មនុស្សទូទៅ មិនស្គាល់ធម៌នេះទេ ។ ក្នុងការគ្រប់គ្រងជីវិតអោយប្រសើរទៅតាមវិធី ពុទ្ធសាសនា ព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកថា ត្រូវគ្រប់គ្រងជីវិតឱ្យប្រព្រឹត្តទៅ ដោយប្រពៃគ្រប់យ៉ាង កុំឱ្យតែអំពើនោះនាំឱ្យកើតក្តីក្តៅក្រហាយដល់ខ្លួនឯង និងអ្នកដទៃ ។

ដើម្បីរស់ មនុស្សសព្វត្រូវប្រកបការងារ ស្វែងរកទ្រព្យសម្បត្តិ ដែលជាមធ្យោបាយឱ្យកើតគ្រឿងឧបភោគបរិភោគ សម្រាប់ចិញ្ចឹមជីវិត ។ ជីវិតអាចរស់នៅបាន អាស្រ័យដោយអាហារ ។ អ្នកណាមានទ្រព្យសម្បត្តិ អ្នកនោះមានជីវភាពខ្ពង់ខ្ពស់ ។ បើមានជីវភាពខ្ពង់ខ្ពស់ទើបមានឋានៈ សមជាមនុស្ស នៅក្នុងលោកនេះ ។ តែការកសាងជីវិតឱ្យខ្ពង់ខ្ពស់ត្រូវស្គាល់ប្រមាណ គឺត្រូវស្វែងរកទ្រព្យសម្បត្តិ ទៅតាមគន្លងធម៌ ការស្វែងរកទ្រព្យសម្បត្តិជាកិច្ចការប្រចាំជីវិតពិតមែន តែត្រូវកុំឱ្យវិនាសដល់ខ្លួន និងអ្នកដទៃ ធ្វើដូចម្តេចឱ្យបានទ្រព្យសម្បត្តិផង ហើយធ្វើឱ្យមានសេចក្តីសុខដល់ខ្លួន និងអ្នកដទៃផង ។ ធ្វើបានយ៉ាងនេះទើបប្រសើរ ។

ការធ្វើខ្លួនឱ្យប្រសើរ និង ការធ្វើជីវិតឱ្យប្រសើរ មានតម្លៃខ្ពង់ខ្ពស់ណាស់ ជាវិធីប្រសើរបំផុត ។ នេះហើយជាវិធីពុទ្ធសាសនា ដែលហៅថា សម្មាជីព " អាជីពត្រឹមត្រូវ " ។

អ្នកស្រឡាញ់ខ្លួន ចង់សាងខ្លួនឱ្យបានជាអរិយជន គួរគប្បីគ្រប់គ្រងជីវិតខ្លួនដោយប្រពៃ ខ្លួនយើងក៏ឱ្យបានសុខ ខ្លួនអ្នកដទៃក៏ឱ្យបានសុខដែរ ហើយវៀរអំពើដែលប្រកបដោយទោស គឺមានទោសដល់ខ្លួនឯងផង ដល់អ្នកដទៃផង ។ ដូចព្រះពុទ្ធតម្រាស់ថា

" ភិក្ខុទាំងឡាយក្នុងពុទ្ធសាសនានេះ គួរលះបង់មិច្ឆាជីព ហើយគួរចិញ្ចឹមជីវិតឱ្យរស់នៅដោយសម្មាជីព ។ ភិក្ខុទាំងឡាយវិធីនេះហៅថា សម្មាអាជីវៈ " ។

អ្នកស្រឡាញ់ខ្លួន គួរវៀរចាកការចិញ្ចឹមជីវិតប្រកបដោយទោស ទោសកើតដល់ខ្លួន កើតដល់អ្នកដទៃ ព្រោះអំពើនេះ នាំទៅកាន់ហាយនភាព។ ឧបាសកក្នុងពុទ្ធសាសនាត្រូវវៀរជំនួញ ៥ ប្រការ ។

**ជំនួញ ៥ ប្រការនោះគឺ :**

| | |
|---|---|
| **១- សត្ថវណិជ្ជា** | ជំនួញសាស្ត្រាវុធ |
| **២- សត្តវណិជ្ជា** | ជំនួញមនុស្ស |
| **៣- មំសវណិជ្ជា** | ជំនួញសាច់ |
| **៤- មជ្ជវណិជ្ជា** | ជំនួញគ្រឿងញៀនគ្រឿងស្រវឹង |
| **៥- វិសវណិជ្ជា** | ជំនួញថ្នាំពុល |

អ្នកដែលវៀរការងារមិនប្រសើរ គឺមិច្ឆាជីព ហើយប្រកបការងារប្រសើរ គឺសម្មាជីព អ្នកនោះ ជាមនុស្សមានកាយបរិសុទ្ធ បាតដៃស្អាត រស់នៅដោយក្តីក្សេមក្សាន្ត ជាជីវិតប្រសើរនៅនាលោកនេះ ឈ្មោះថាបានកសាងខ្លួនជាមនុស្សពេញលក្ខណៈឡើងឋានៈ ជាអរិយជន សមទៅតាមសេចក្តីប្រាថ្នាមនុស្សលោក ។ ដូច្នេះគួរសាធុជនវៀរនូវមិច្ឆាជីពនេះចោលបង់ ។ នេះជាវិធីដែលព្រះសម្ពុទ្ធទ្រង់សរសើរ ។

កត្តាទាំង ៣ ប្រការគឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវ នៃមាគ៌ាប្រកបដោយអង្គ ៨ ហៅថាពួក សីល ឬ សីលខន្ធ ។ នេះជាសីលដែលមនុស្សលោកត្រូវប្រតិបត្តិ ជាសីលធម៌នាំមនុស្សលោកទៅវិថីប្រសើរ សុខដុមរមនានឹងគ្នានៅនាលោកនេះ សម្រាប់បុគ្គលម្នាក់ៗ ឬសម្រាប់សង្គមមនុស្សលោកទាំងមូល ។ សីលធម៌នេះ ជាដើមនៃកុសលធម៌ទាំងពួង លោកទុកជាគ្រឹះចាំបាច់ខានពុំបាន ដើម្បីនឹងបានលុះធម៌ជាន់ខ្ពស់ទៅទៀត ។ បើមិនមានគុណធម៌នេះទុកជាគ្រឹះ ឬទុកជាបាទទេ បុគ្គលមិនអាចនឹងឡើងទៅកាន់គុណធម៌ជាន់ខ្ពស់ជាលំដាប់ទៅទៀតបានទេ ។

ដកស្រង់ពីអត្ថបទ " ទស្សនវិជ្ជាពុទ្ធសាសនា " របស់
ព្រះវិរិយបណ្ឌិតោភិក្ខុ **ជ័ន ខាត់**
ពោះពុម្ព ឆ្នាំ ១៩៦៨

បោះពុម្ពនៅរោងពុម្ពរណសិរ្ស ២ ធ្នូ